# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍បឹងរំពេរ

## រយៈពេល ៣ ឆ្នាំ

## (២០១៧ ដល់២០១៩)

សហគមន៍នេសាទ : បឹងរំពេរ

ភូមិ : ចំបក់

ភូមិ : សង់ឃ្លាំង

ភូមិ : ទួលវិហារ

ឃុំ : តាំងក្រសាំង

ឃុំ : ជ្រាប់

ស្រុក : សន្ទុក

ខេត្ត : កំពង់ធំ

# មាតិកា


**១. ស្ថានភាពទូទៅ** ........ 3

**២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម** ........ 4

ក-ប្រជាពលរដ្ឋ: ........ 4

ខ-មុខរបរ ........ 5

**៣. កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍** 6

ក. ទីតាំង ........ 6

ខ. ដែននេសាទ ........ 6

គ. កន្លែងដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស ........ 6

ឃ. ធនធានជលផល ........ 6

**៤. ការធ្វើនេសាទ** ........ 7

ក. អ្នកនេសាទ ........ 7

ខ. ឧបករណ៍នេសាទ ........ 7

គ. ប៉ាន់ប្រមាណ ផលចាប់នេសាទប្រចាំឆ្នាំ ........ 9

**៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍** ........ 9

ក. ទស្សនៈវិស័យ ........ 9

ខ. គោលបំណង ........ 10

គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ........ 10

គ.១- ផែនការប្រើប្រាស់ឧបករណ៍នេសាទ ........ 10

គ.២ ផែនការកែលម្អរដែននេសាទ ........ 12

គ.៣ រៀបចំកន្លែងអភិរក្ស ........ 12

គ.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក ........ 13

គ. ៥ ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ........ 14

គ. ៥ ផែនការអភិវឌ្ឍន៍មុខរបរទ្រទ្រង់ជីវភាព ........ 14

គ.៦ ផែនការអភិវឌ្ឍន៍កម្មវិធីចំរុះ ........ 15

គ. ៧ ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ ........ 15

គ.៨ ផែនការផ្សព្វផ្សាយបណ្តុះបណ្តាលបង្កើនការយល់ដឹង ........ 15

គ. ៩ ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ........ 16

ឃ. យុទ្ធសាស្ត្រ ........ 16

តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍នេសាទបឹងរំពេររយៈពេល ៣ ឆ្នាំ (២០១៧ ដល់ ២០២០) 18

តារាងកម្មវិធីការងារ ........ 23

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

## ១. ស្ថានភាពទូទៅ

សហគមន៍នេសាទ បឹងរំពេរ មានទីតាំងស្ថិតនៅភូមិ ចំបក់ សង់ឃ្លាំង ឃុំតាំងក្រសាំង និងភូមិទួលវិហារ ឃុំជ្រាប់ ស្រុកសន្ទុក ខេត្តកំពង់ធំ។ សហគមន៍នេះ មាន ៤៧៦ គ្រួសារ សមាជិកសរុបចំនួន ៥០៩ ស្រី ២០៩នាក់ និងមានគណៈកម្មការសហគមន៍ ០៩នាក់ ស្ត្រី ០២នាក់។

សហគមន៍នេសាទនេះ ត្រូវបានបង្កើតឡើង មហាសន្និបាទលើកដំបូង នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ ២០០៦ និងបានធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ចុះថ្ងៃទី១៩ ខែ មេសា ឆ្នាំ២០០៧។

កន្លងមកសហគមន៍នេសាទនេះបានដំណើរការសកម្មភាពសំខាន់ៗរបស់ខ្លួន រួមមានៈ

- ចុះបញ្ជីសមាជិកសហគមន៍នេសាទ និងប្រមូលប្រាក់សមាជិកភាពបាន នៃសមាជិករបស់ខ្លួន។
- បានបោះបង្គោល និងលើកស្លាកតំបន់អភិរក្ស បាន២កន្លែង។
- បានរៀបចំលក្ខន្តិកៈ និងបទបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ និងអនុម័តអោយប្រើប្រាស់ដោយមហាសន្និបាតនៅថ្ងៃទី ១៤ ខែមីនា ឆ្នាំ ២០០៦ ។
- បានរៀបចំធ្វើមហាសន្និបាតកំណើតដំបូងថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០៦។
- បានកំណត់ព្រំប្រទល់ និងមានផែនទីកន្លែងនេសាទសហគមន៍ ដែលមានទំហំផ្ទៃដីសរុប ១២០ ហិចតា។
- បានចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ជាមួយការិយាល័យជលផល ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ២០០៧។
- បានពិភាក្សារៀបចំធ្វើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍។
- បានផ្សព្វផ្សាយសារៈប្រយោជន៍នៃតំបន់អភិរក្ស និងព្រៃលិចទឹក។
- បានរៀបចំក្រុមល្បាតចំនួន ០៣ ក្រុម(ក្រុមនីមួយៗមានសមាជិក ០៤នាក់)។
- បានរៀនសូត្របច្ចេកទេសបណ្តុះផ្សិត ចិញ្ចឹមត្រីអណ្តែង ជន្លេន និងសាកល្បងអនុវត្តដាំ និងចិញ្ចឹមបានចំនួន២១គ្រួសារ
- ដោយមានការឧបត្ថម្ភថវិកាដោយអង្គការ FACT UNDP GEF SGP សហគមន៍មានលទ្ធភាពរៀបចំ និងអនុវត្តការងារមួយចំនួនដូចខាងក្រោមបន្ថែមទៀត ។
- រៀបចំកន្លែងអភិរក្សត្រីមេពូជ ០១កន្លែង ទំហំ ៥,៥ ហិចតា ដោយមានការបោះបង្គោលកំណត់ព្រំប្រទល់ចំនួន ៧០ ដាក់លូធ្វើជាជំរកត្រីចំនួន ២០លូ និងទំលាក់គល់ឈើចំនួន ៧០កំណាត់ និងបោះស្លាកបំរាមនៅកន្លែងអភិរក្សចំនួន ៥ស្លាក
- បោះស្លាកសញ្ញាសំគាល់សហគមន៍នេសាទបឹងរំពេរចំនួន២ផ្ទាំង (ស្លាកធំ) និង ស្លាកធំ ១។
- ដាំព្រៃលិចទឹកបានចំនួន ១៦១២៨ដើម លើផ្ទៃដី ០៨ហិចតា នៅជុំវិញបឹងរំពេរ។
- បានបោះបង្គោលព្រំប្រទល់សហគមន៍ចំនួន ១១០ បង្គោល។

- បានរៀបចំបណ្តាញស្ត្រីចំនួន ១៥នាក់(១ភូមិ ៥នាក់ ក្នុង ៣ភូមិ គឺភូមិចំបក់ សង់ឃ្លាំង និងទួលវិហារ)។
- បានរៀបចំបណ្តាញសហគមន៍ថ្នាក់ឃុំ ២នាក់។
- បានរៀបចំវគ្គអប់រំផ្សព្វផ្សាយស្តីពីទស្សនៈក្រុមសន្សំប្រាក់ដល់ប្រជាពលរដ្ឋនៅភូមិសង់ឃ្លាំង ចំបក់ និងទួល វិហារចំនួន ១លើក មានប្រជាពលរដ្ឋចូលរួម ១៤៥នាក់ ស្ត្រី ១២៨នាក់។
- បានពិភាក្សាកំណត់ និងបែងចែកតំបន់គ្រប់គ្រង និងដាំព្រៃលិចទឹកទៅតាមភូមិនីមួយៗ។
- បានគាំទ្រក្រុមសន្សំប្រាក់ចំនួន ៦ក្រុម ដែលមានសមាជិកសរុប ១២៩នាក់ ។
- បានប្រារព្ធទិវាលែងកូនត្រីបានចំនួន ៤៥០០០ក្បាល ទៅក្នុងកន្លែងអភិរក្សពូជត្រីរបស់សហគមន៍។
- បានចុះល្បាត និងអប់រំបទល្មើសនេសាទក្នុងដែននេសាទ របស់សហគមន៍។
- គណៈកម្មការសហគមន៍ចូលរួមដំណើរការកម្មវិធីវិនិយោគឃុំ/សង្កាត់។
- បណ្តុះបណ្តាលដល់ ជនបង្គោលយេនឌ័រ គណៈកម្មការសហគមន៍ ស្តីអំពីតួនាទីការងារយេនឌ័រ សមធម៌ យេនឌ័រ និង ការប្រែប្រួលអាកាសធាតុ។
- ផ្តល់វគ្គបណ្តុះបណ្តាល ស្តីពីវិធីសាស្រ្តវិភាគសហគមន៍ ឆ្ពោះទៅកាន់និរន្តរភាពសហគមន៍មូលដ្ឋាន។
- ធ្វើវេទិការតុមូលថ្នាក់ឃុំស្តីអំពីសិទ្ធិនៃសេចក្តីសម្រេចចិត្ត និងភាពជាអ្នកដឹកនាំតួនាទីការទទួលខុសត្រូវក្នុងសង្គមរបស់ យុវជន ព្រមទាំងសុខភាព ការបោះបង់ការសិក្សា ប្រើប្រាស់គ្រឿងញៀន អ្នកចូលរួម ៣១នាក់។
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីអំពី ការដឹកនាំ ចាត់ចែង និងគ្រប់គ្រងបញ្ញើស្នាម ថវិកា គោលការណ៍ប្រើប្រាស់ថវិកា ការ បិទបញ្ជីស្នាម។
- បានគាំទ្រកញ្ចប់ថវិកាសំរាប់ បង្កើនជីវភាពរបស់សមាជិកអង្គការមហាជន តាមរយៈការចិញ្ចឹមត្រី ចិញ្ចឹមសត្វ ដាំដំណាំ ជាលក្ខណៈគ្រួសារ ២៥គ្រួសារ។

ដោយមានការជួយគាំទ្រពីអង្គការFACT, UNDP-GEF-SGP និងការិយាល័យជលផលខេត្តកំពង់ធំ សហគមន៍នេសាទបឹង រំពេរបានទទួលសម្ភារៈប្រើប្រាស់មួយចំនួនដូចខាងក្រោម៖

- ទូកល្បាតចំនួន ០១គ្រឿង
- ម៉ាស៊ីនកាណូត ០១គ្រឿង
- ម៉ាស៊ីនថត ០១ គ្រឿង
- ទូរស័ព្ទដៃ ០៣ គ្រឿង
- ហិបប្រាក់ភាគទានទ្រទ្រង់សហគមន៍ចំនួន ០១។

## ២. អំពីប្រជាសាស្រ្ត និងសេដ្ឋកិច្ចសង្គម

### ក-ប្រជាពលរដ្ឋ:

តាមទិន្នន័យរបស់ឃុំក្នុងឆ្នាំ២០១៥ ប្រជាពលរដ្ឋរស់នៅក្នុងឃុំតាំងក្រសាំង មានចំនួនសរុប ៤,១៧៥ គ្រួសារ ស្រី ២,០៦៤ នាក់ ក្នុងនោះមានស្រ្តីមេម៉ាយ ១០៤ គ្រួសារ ជនពិការ ២០ នាក់ ស្រី ៥ នាក់ ចាស់ជរា៣២នាក់ ស្រី១៦នាក់ កុមារ កំព្រា៦នាក់ ស្រី២នាក់ អ្នកមានជំងឺរាំរ៉ៃក្នុងសហគមន៍១៤នាក់ ស្រី៤នាក់ ប្រជាពលរដ្ឋកាន់សាសនាព្រះពុទ្ធប្រមាណ៣,៩៦៧ នាក់ ក្រៅពីនេះមានអ្នកកាន់សាសនាកាតូលិកប្រមាណ២៨នាក់។ ក្នុងចំណោមសមាជិកសហគមន៍នេសាទ មានអ្នកមិនចេះ

អក្សរចំនួន៣៨០នាក់ រៀនបានត្រឹមកំរិតថ្នាក់បឋមសិក្សាចំនួន៩៥២នាក់ កំរិតមធ្យមសិក្សាចំនួន២៥០នាក់ និងកំរិតថ្នាក់ឧត្តមសិក្សាចំនួន១៥នាក់។

**ខ-មុខរបរ**

ចំនួនមុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍រួមមានៈ

- នេសាទត្រីចំនួន ២.៩២២គ្រួសារ ។
- ធ្វើស្រែចំនួន ៣.១០០ គ្រួសារ លើទំហំផ្ទៃដី៣.៧២៩ហិចតា
- ចំនួនអ្នកធ្វើចំការ ៥៥គ្រួសារ លើផ្ទៃដី៤៧ហិចតា
- ដាំដំណាំបន្លែមចំនួន ២០គ្រួសារ លើទំហំផ្ទៃដី ៣ហិចតា
- ជាងផ្ទះ ចំនួន ៣៨ គ្រួសារ
- ចំនួនអ្នកលក់ដូរ ១១៧គ្រួសារ
- ចំនួនកែច្នៃផលនេសាទ ២៥គ្រួសារ
- ចំនួនអ្នកចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ ៣៥០គ្រួសារ
- ចំនួនអ្នករត់ម៉ូតូឌុប ២១គ្រួសារ
- ចំនួនអ្នករត់រថយន្តឈ្នួល ៦គ្រួសារ
- ចំនួនអ្នកដឹងទំនិញលក់ ៥គ្រួសារ
- ចំនួនអ្នកឡើងត្នោត ៧នាក់
- ចំនួនអ្នកស៊ីឈ្នួលគេ (កម្មករសំណង់) ៥៥០ នាក់
- ចំនួនពេទ្យសត្វ ៣នាក់
- ចំនួនគ្រូពេទ្យ ៧នាក់
- ចំនួនឆ្មបភូមិ ៥នាក់
- ចំនួនជាងជួសជុលម៉ាស៊ីន ២នាក់
- ចំនួនជាងផ្សារដែក៩នាក់
- ចំនួនជាងកាត់សក់២នាក់
- ចំនួនជាងកាត់ដេរសំលៀកបំពាក់៤នាក់
- ចំនួនគ្រូបុរាណ៧នាក់
- ចំនួនកម្មកររោងចក្រ២៧នាក់
- ចំនួនអ្នកលេងភ្លេងខ្មែរ ៧នាក់
- ចំនួនអ្នកសាកអាគុយ ៣នាក់
- ចំនួនអ្នកបើករបរកិនស្រូវ ៣៣នាក់
- ចំនួនដេរប៉ូលក់គ្រឿងសំណង់ ០២នាក់
- ចំនួនជាងកំបោរ ៩ នាក់
- ចំនួនជួលរោងការ និងចុងភៅ ០៤នាក់
- ចំនួនអ្នកមានហាងលក់បាយ ២នាក់
- ចំនួនអ្នកលក់គ្រឿងទេសន៍ ៣៣នាក់

## ៣. កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍

### ក. ទីតាំង

កន្លែងនេសាទសហគមន៍នេសាទបឹងរំពេរ ដែននេសាទទឹកសាបមានលក្ខណៈជាបឹងជាកន្លែងនេសាទសាធារណៈរបស់រដ្ឋ។ កន្លែងសហគមន៍នេសាទនេះមានទំហំ**១២០ ហិចតា** និងមានកំណត់និយាមកាដូចមានចែងក្នុងកិច្ចព្រមព្រៀង។

សហគមន៍នេសាទបឹងរំពេរមានព្រំប្រទល់ ៖

- ខាងជើងទល់នឹង ដីស្រែភូមិទួលវិហារ
- ខាងត្បូងទល់នឹង ស្ទឹងជីនិត
- ខាងកើតទល់នឹង ចំបក់
- ខាងលិចទល់នឹង វាលរំពេរ(វាលស្រែ)

### ខ. ដែននេសាទ

**កន្លែងនេសាទសហគមន៍ បឹងរំពេរមានបឹងចំនួន២ និងអូរចំនួន ០២**

- បឹងរំពេរមានទំហំ ៦២,១៣ហិចតា ការនេសនេសាទត្រី ចាប់ពីខែ១ ដល់ខែ១២
- បឹងខ្សុង ទំហំ ៣,៥៦ហិតា ការនេសាទត្រីចាប់ពី ខែ៧ ដល់ ខែ១
- អូរកៀនទៀក ទំហំ ៦ហិតា ការនេសាទត្រីចាប់ពីខែ ៧ដល់ ខែ២
- អូរអង្គរអន ទំហំ ១៥ហិតា នេសាទត្រីចាប់ពីខែ១ ដល់ ខែ២
- ក្រៅពីនោះមានព្រៃលិចទឹក និងព្រៃបោះ ទំហំ ១៣,៤៤ ហិតា
- វាលស្រែបោះបង់ ដុះព្រៃរបោះ ២៤,៩៦ហិតា

### គ. កន្លែងដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស

- អន្លង់បឹងរំពេរ ទំហំ ០៧ ហិតា (សម្រាប់អភិរក្សត្រីមេពូជ)
- អន្លង់កោះទុង ទំហំ ០៣ ហិតា (សម្រាប់អភិរក្សត្រីមេពូជ)
- អភិរក្សព្រៃលិចទឹក ទំហំ ១៣,៣១ ហិតា(ព្រៃអភិរក្សកោះទុង)

### ឃ. ធនធានជលផល

- **ប្រភេទត្រីមាន៖** ត្រីរ៉ស់ ឆ្តោរ រៀល ស្លាត ឆ្លាំង ក្រម៉ម អណ្តែង ច្រវ៉ា កំភ្លាញ ឆ្លូញ ក្រាញ់ ខ្មាន់ ឆ្ពិន ច្រកែង កន្ទ្រប់ ដំរីកញ្ចុះ ក្រុស ផ្ទោង កញ្ចាញ់ច្រាស់ កញ្ជ្រូក ត្រីខ្សាច់ កាហែ កំភ្លៀវ លិញ ត្រនេល សណ្តាយ ច្រលឹង ព្រលូង ស្លឹកឬស្សី ខ្ជឹង ។ល។
- **ប្រភេទសត្វស្លាបមាន៖** សត្វកុកស កុកក្រក មាន់ទឹក ទោម ប្រវឹក ខ្លុំ ទាព្រៃ រនាលខ្សុង ក្រសារ គ្រដក់ ក្អែកទឹក ស្មោញ អែអូត ។ល។
- **ប្រភេទរុក្ខជាតិព្រៃលិចទឹក និងរាវីរុក្ខជាតិមាន៖** ដើមរាំង ក្ទំក្អែង អញ្ចាញ ត្រស់ សណ្តាន់ បបួយ តាអួរ ក្រឡុក ខ្ទម្ពទៀនព្រៃ ថ្លើមអណ្តើក ខ្នាយមាន់ កណ្តាប់ចង្កេរ តាសែង ញរ សាច់ខ្មៅ ប្រជេញ វល្លិ៍ព្រេង ឈ្លើយ ល្ពាក់ វល្លិ៍ដូងព្រះ វល្លិ៍តាអើក កំប្លោក កំពីងពួយ ចក ស្មៅ ត្រកួន កញ្ឆែត ស្លាបប្រវា សារាយ ក្រចាប់ ព្រលិត រំចង់។ល។

## ៤. ការធ្វើនេសាទ

### ក. អ្នកនេសាទ

មុខរបរនេសាទក៏ជារបរមួយយ៉ាងសំខាន់របស់សមាជិកសហគមន៍ និងអ្នកនេសាទដែលរស់នៅភូមិជិតខាង និងអ្នកក្រៅតំបន់ ដែលប្រើឧបករណ៍ និងមធ្យោបាយ នេសាទ ដូចមាន ខាងក្រោមនេះ ៖

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន ៤៧៥ នាក់ ស្រី ១៥០ នាក់។
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទ នៅក្នុងសហគមន៍មានចំនួន ៣៨០នាក់ស្ត្រី ៨០នាក់ ។
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន ៥០ គ្រួសារ។

### ខ. ឧបករណ៍នេសាទ

**ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍**

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ. ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ.......) |
|---|---|---|---|---|
| មង | ត្បូង(១០០ម) | ១៦០ (១៦០នx១ត្បូង) | -ក្រឡា=២.៥សម<br>-សំរុង=១.៥ម<br>-ប្រវែង=១៦០០០ម | ខែ០១ ដល់ ខែ ១២ |
| សន្ទូច | ផ្លែ | ១០៥០០០ (៣៥នx៣០០ផ) | -ផ្លែលេខ=១៤-១៦ | ខែ០៧ ដល់ ខែ ១០ |
| សំណាញ់ | វង់ | ៣០ (៣០នx១វង់) | - ក្រឡា=២,៥សម<br>- សំរុង=៦ម | ខែ០១ ដល់ ខែ ១២ |
| បបក់ | ផ្លែ | ០៧ (៧នx១ផ) | - ផ្លែច្នៃខ្លួនឯង | ខែ ១០ ដល់ ១១ |
| បង្កៃ | ផ្លែ | ៤៦០ (៨នx៨០ផ) | - ផ្លែលេខ ១៤-១៦ | ខែ ១១ ដល់ ០៤ |
| ព្រយុង | វង់ (៥០ម) | ២០ (២០នx១វង់) | - ក្រឡា ១,៥សម<br>- សំរុង ៥ម<br>- ប្រវែង ១០០០ម | ខែ ១០ ដល់ ១២ |
| លបលួង | គ្រឿង | ៣០០ (១៥នx២០ម) | -ទំហំ ០,៤ម x១,២ម<br>-ចន្លោះគ្រៀម ១,៥សម | ខែ០៦ ដល់ ខែ ០៨ |
| លបត្រីដំរី | គ្រឿង | ៤៥ (៣នx១៥គ) | -ទំហំ ០,៤០ម x ១,២ម<br>-ចន្លោះគ្រៀម ១,៥សម | ខែ០១ ដល់ ខែ ១២ |
| អង្រុត | គ្រឿង | ៧ (៧នx១គ) | | ខែ០២ ដល់ ខែ ០៤ |
| មងវាយ | វង់ (៥០ម) | ៤ (៤x១វង់) | - ក្រឡា ៣,៥សម<br>- សំរុង ២,៥ ម<br>- ប្រវែង ២០០ម | ខែ ០៣ ដល់ ០៤ |

## ៤. ការធ្វើនេសាទ

### ក. អ្នកនេសាទ

មុខរបរនេសាទក៏ជារបរមួយយ៉ាងសំខាន់របស់សមាជិកសហគមន៍ និងអ្នកនេសាទដែលរស់នៅភូមិជិតខាង និងអ្នកក្រៅតំបន់ ដែលប្រើឧបករណ៍ និងមធ្យោបាយ នេសាទ ដូចមាន ខាងក្រោមនេះ ៖

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន ៤៧៥ នាក់ ស្រី ១៩០ នាក់។
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទ នៅក្នុងសហគមន៍មានចំនួន ៣៨០នាក់ស្ត្រី ៨០នាក់ ។
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន ៥០ គ្រួសារ។

### ខ. ឧបករណ៍នេសាទ

**ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍**

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ. ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ.......) |
|---|---|---|---|---|
| មង | ត្បូង(១០០ម) | ១៦០<br>(១៦០នx១ត្បូង) | -ក្រឡា=២.៥សម<br>-សំរុង=១.៥ម<br>-ប្រវែង=១៦០០០ម | ខែ០១ ដល់ ខែ ១២ |
| សន្ទូច | ផ្លែ | ១០៥០០០<br>(៣៥នx៣០០៨) | -ផ្លែលេខ=១៤-១៦ | ខែ០៧ ដល់ ខែ ១០ |
| សំណាញ់ | វង់ | ៣០<br>(៣០នx១វង់) | - ក្រឡា=២,៥សម<br>- សំរុង=៦ម | ខែ០១ ដល់ ខែ ១២ |
| បបក់ | ផ្លែ | ០៧<br>(៧នx១ផ) | - ផ្លែច្នៃខ្លួនឯង | ខែ ១០ ដល់ ១១ |
| បង្កៃ | ផ្លែ | ៤៦០<br>(៨នx៨០ផ) | - ផ្លែលេខ ១៤-១៦ | ខែ ១១ ដល់ ០៤ |
| ព្រយុង | វង់<br>(៥០ម) | ២០<br>(២០នx១វង់) | - ក្រឡា ១,៥សម<br>- សំរុង ៥ម<br>- ប្រវែង ១០០០ម | ខែ ១០ ដល់ ១២ |
| លបលួង | គ្រឿង | ៣០០<br>(១៥នx២០ម) | -ទំហំ ០,៤ម x១,២ម<br>-ចន្លោះគ្រៀម ១,៥សម | ខែ០៦ ដល់ ខែ ០៨ |
| លបត្រីដំរី | គ្រឿង | ៤៥<br>(៣នx១៥គ) | -ទំហំ ០,៤០ម x ១,២ម<br>-ចន្លោះគ្រៀម ១,៥សម | ខែ០១ ដល់ ខែ ១២ |
| អង្រុត | គ្រឿង | ៧<br>(៧នx១គ) | | ខែ០២ ដល់ ខែ ០៤ |
| មងវាយ | វង់<br>(៥០ម) | ៤<br>(៤x១វង់) | - ក្រឡា ៣,៥សម<br>- សំរុង ២,៥ ម<br>- ប្រវែង ២០០ម | ខែ ០៣ ដល់ ០៤ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំឡាំងសេះ |
|---|---|---|---|
| ទូកកំពោល ភ្ជាប់ម៉ាស៊ីនមួយទឹក | ១៧៥ គ្រឿង | ៧០០-៨០០គក្រ | ៥-៩ សេះ |
| ទូកភ្ជាប់ម៉ាស៊ីន | ៣៥គ្រឿង | ១០០០-១៥០០គក្រ | ១៥-២៤ សេះ |
| ទូកអុំ ឬចែវ | ២៦៥គ្រឿង | ២០០-៣០០គក្រ | គ្មាន |

ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកនៅក្នុងតំបន់ ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ. ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ...........ដល់ខែ.........) |
|---|---|---|---|---|
| មង | ត្បូង(១០០ម) | ១០០<br>(១០០នx១ត) | -ក្រឡា=២,៥សម<br>-សំរុង=១,៥ម<br>-ប្រវែង=១៦០០០ម | ខែ០១ ដល់ ខែ ១២ |
| សន្ទូច | ផ្លែ | ៦០០០<br>(៣៥នx៣០០ផ) | -ផ្លែលេខ=១៤-១៦ | ខែ០៧ ដល់ ខែ ១០ |
| សំណាញ់ | វង់ | ១០<br>(១០នx១វង់) | - ក្រឡា=២,៥សម<br>- សំរុង=០៦ម | ខែ០១ ដល់ ខែ ១២ |
| បបក់ | ផ្លែ | ០៣<br>(៣នx១ផ) | - ផ្លែច្នៃខ្លួនឯង | ខែ ១០ ដល់ ខែ ១១ |
| បង្កៃ | ផ្លែ | ៤៦០<br>(៨នx៨០ផ) | - ផ្លែលេខ ១៤-១៦ | ខែ ១១ ដល់ ខែ ០៤ |
| ព្រយុង | វង់<br>(៥០ម) | ០៧<br>(៧នx១វង់) | - ក្រឡា ១,៥សម<br>- សំរុង ៥ម<br>- ប្រវែង ១០០០ម | ខែ ១០ ដល់ ខែ ១២ |
| .លបលួងង | គ្រឿង | ១៦០<br>(៨នx២០គ) | -ទំហំ ០.៤មx១,២ម<br>-ចន្លោះគ្រៀម ១,៥សម | ខែ០៦ ដល់ ខែ ០៨ |
| អង្រុត | គ្រឿង | ៥<br>(៥នx១គ) | | ខែ០២ ដល់ ខែ ០៤ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំឡាំងសេះ |
|---|---|---|---|
| ទូកកំពោល ភ្ជាប់ម៉ាស៊ីនជជុះ | ១៦៣ គ្រឿង | ៧០០-៨០០គក្រ | ៥-៩ សេះ |
| ទូកភ្ជាប់ម៉ាស៊ីនម៉ាស៊ូត | ២៧ គ្រឿង | ១០០០-១៥០០គក្រ | ១៥-២៤ សេះ |
| ទូកអុំ ឬចែវ | ១៩០គ្រឿង | ២០០-៣០០គក្រ | គ្មាន |

ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកមិនមែនជាសមាជិកដែលមកពីខាងក្រៅសហគមន៍នេសាទ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ. ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ......ដល់ខែ......) |
|---|---|---|---|---|
| មង | ត្បូង(១០០ម) | ៧០ (៧០នx១គ) | -ក្រឡា=២,៥សម<br>-សំរុង=១,៥ម<br>-ប្រវែង=១៦០០០ម | ខែ០១ ទៅ ខែ ១២ |
| សន្ទូច | ផ្លែ | ៣៥០០ (១០នx៣០០ផ) | -ផ្លែលេខ=១៤-១៦ | ខែ០៧ ទៅ ខែ ១០ |
| សំណាញ់ | វង់ | ៨០ (៨០នx១វង់) | - ក្រឡា=២,៥សម<br>- សំរុង=១០ហាត់ | ខែ០១ ទៅ ខែ ១២ |
| ព្រយុង | វង់ (៥០ម) | ០៣ (៣នx១វង់) | - ក្រឡា ១,៥សម<br>- សំរុង ៥ម<br>- ប្រវែង ១៥០ម | ខែ ១០ -ខែ ១២ |
| លាន់ | គ្រឿង | ៤៥០ (៣នx១៥០ម) | -ទំហំ ០,១០ម<br>-ប្រវែង ១,២ម | ខែ០១ ទៅ ខែ ១២ |
| ចរវ | គ្រឿង (៤ម) | ០២ (២នx១គ) | - ក្រឡា ២,៥ សម<br>- សំរុង ២,៥ម<br>- ប្រវែង ៨ម | ខែ០១ ទៅ ខែ ១២ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំឡាំងសេះ |
|---|---|---|---|
| ទូកកំរោល ភ្ជាប់ម៉ាស៊ីនជជុះ | ១៣ គ្រឿង | ៥០០-៧០០គក្រ | ៥-៩ សេះ |
| ទូកអ៊ុំ ឬចែវ | ៣៧ គ្រឿង | ២០០-៣០០គក្រ | |

**គ. ប៉ាន់ប្រមាណ ផលចាប់នេសាទប្រចាំឆ្នាំ**

| ប្រភេទលផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ *(គិតជា គក)* | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី | ៦០ គីឡូក្រាម | ៤០ គីឡូក្រាម | ១០០ គីឡូក្រាម |
| ខ្យង ខ្ចៅ លៀស | ២០ គីឡូក្រាម | ១០ គីឡូក្រាម | ៣០ គីឡូក្រាម |
| សរុប | ៨០ គីឡូក្រាម | ៥០ គីឡូក្រាម | ១៣០ គីឡូក្រាម |

## ៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ក. ទស្សនៈវិស័យ

សហគមន៍នេសាទ **បឹងរំពេរ** មានទស្សនៈវិស័យ គឺរួមចំណែកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋស្របតាមគោលនយោបាយរបស់ រដ្ឋាភិបាល។

## ខ. គោលបំណង

- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌។
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍តាមរយៈការអភិវឌ្ឍន៍ចំរុះដោយមានការចូលរួម។
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ នឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់ផ្ទាល់លើធនធានធម្មជាតិ។

## គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### គ.១- ផែនការប្រើប្រាស់ឧបករណ៍នេសាទ

#### គោលបំណង

- គ្រប់គ្រង អភិរក្ស ប្រើប្រាស់ធនធានជលផលអោយបានសមស្រប និងធ្វើអោយប្រសើរឡើងវិញនូវធនធានជលផលនៅក្នុងកន្លែងនេសាទសហគមន៍ប្រកបដោយនិរន្តភាព។
- កាត់បន្ថយការប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់ និងកាត់បន្ថយទំនាស់នៅក្នុងកន្លែងនេសាទសហគមន៍។
- បង្កើនការយល់ដឹងពីការគ្រប់គ្រងធនធានជលផលនៅក្នុងតំបន់គ្រប់គ្រងដោយសហគមន៍។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរអំពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោមៈ

| ឈ្មោះ/ទីតាំង/កន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតអោយប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| បឹងរំពេរ | ១ - ១២ | មង | -ក្រឡាចាប់ពី ៣ស.មឡើង<br>-សំរ៉ុង ១,៥ម<br>-ប្រវែង=៣៥០ម | ៧នាក់<br>(១ន ៥០ម) | |
| | | លាន់ | -ទំហំ ០,១០ម<br>-ប្រវែង=១,២ម | ៣នាក់=៤៥គ<br>(១ន=១៥ម) | |
| | | អង្រុត | | ១០ន<br>(១ន=១គ) | |
| | | សន្ទូច | -ផ្លែលេខ(១៤-១៨)<br>ចំនួន ៥០០ផ | ៥ន=៥០០ផ<br>(១ន=១០០ផ) | |
| | | ប្របក់ | | ៧ន<br>(១ន=១០០ផ) | |
| | | បង្កៃ | -ផ្លែលេខ(១៤-១៨)<br>-ចំនួន ១០០ផ | ៥ នាក់<br>(១ន=២០ផ) | |
| បឹងតូច | ខែ ៧-ខែ ២ | មង | -ក្រឡាចាប់ពី ៣ស.មឡើង<br>-សំរ៉ុង ១,៥ម<br>-ប្រវែង=១០០ម | ២នាក់=១០០ម<br>(១ន=៥០ម) | |

| | | | | | |
|---|---|---|---|---|---|
| | | លាន់ | -ទំហំ ០,១០ម<br>-ប្រវែង=១,២ម | ២នាក់=៣០គ<br>(១ន=១៥ម) | |
| | | អង្រុត | | ៥ នាក់ | |
| | | សំណាញ់ | -ក្រឡា=២,៥ ស.មឡើង<br>-ប្រវែង ០៦ម | ២នាក់ | |
| | | សន្ទូច | ផ្លែលេខ(១៤-១៨)<br>ចំនួន ២០០ផ | ២នាក់= ២០០ផ(១<br>ន=១០០ផ) | |
| | | ប្របក់ | | ៤នាក់ | |
| | | បង្កៃ | ផ្លែលេខ(១៤-១៨)<br>ចំនួន ២០៤ផ | ២ នាក់= ៤០ផ<br>(១ន=២០ផ) | |
| អូរកៀនទៀក | ខែ ៧-ខែ២ | មង | -ក្រឡាចាប់ពី ៣សមឡើង<br>-សំរុង ១,៥ម<br>-ប្រវែង=១០០ម | ២នាក់=១០០ម<br>(១ន=៥០ម) | |
| | | លាន់ | -ទំហំ ០,១០ម<br>-ប្រវែង=១,២ម | ២នាក់=៣០គ<br>(១ន=១៥ម) | |
| | | អង្រុត | | ៥ នាក់ | |
| | | សំណាញ់ | -ក្រឡា=២,៥ ហ៊ុនឡើង<br>-ប្រវែង ០៦ | ២នាក់ | |
| | | សន្ទូច | ផ្លែលេខ(១៤-១៨)<br>ចំនួន ២០០ផ | ២នាក់= ២០០ផ<br>(១ន=១០០ផ) | |
| | | បបក់ | កែផ្នែខ្លួនឯង | ៤នាក់<br>(១ន=១ផ) | |
| | | បង្កៃ | ផ្លែលេខ(១៤-១៨)<br>ចំនួន ២០៤ផ | ២ នាក់= ៤០ផ<br>(១ន=២០ផ) | |
| អូរអង្គរអេន | ខែ ១-ខែ១២ | មង | -ក្រឡាចាប់ពី ៣សមឡើង<br>-សំរុង ១,៥ម<br>-ប្រវែង=១០០ម | ២នាក់=១០០ម<br>(១ន=៥០ម) | |
| | | លាន់ | -ទំហំ ០,១០ម<br>-ប្រវែង=១,២ម | ២នាក់=៣០គ<br>(១ន=១៥ម) | |
| | | អង្រុត | ចំនួន ៥គ | ៥ នាក់ | |
| | | សំណាញ់ | -ក្រឡា=២,៥ សមឡើង<br>-ប្រវែង ០៦ម | ៣នាក់ | |
| | | សន្ទូច | ផ្លែលេខ(១៤-១៨)<br>ចំនួន ២០០ផ | ២នាក់= ២០០ផ<br>(១ន=១០០ផ) | |
| | | បបក់ | ៤ផ | ៤នាក់<br>(១ន=១ផ) | |

| | | | | | |
|---|---|---|---|---|---|
| | | បង្កៃ | ផ្លែលេខ(១៤-១៨) ចំនួន ៤០ផ | ២ នាក់= ៤០ផ (១ន=២០ផ) | |

**គ.២ ផែនការកែលម្អដែននេសាទ**

**គោលបំណង**

- រក្សាទឹកនៅក្នុងបឹងរបស់សហគមន៍អោយបានច្រើន និងទប់ទល់នូវភាពរាំងស្ងួត ជាពិសេសនៅរដូវប្រាំង ដើម្បីអោយមានត្រីច្រើនក្នុងបឹង
- ទាក់ទាញការចូលរួមគ្រប់គ្រងធនធានជលផល និងលើកស្ទួយកំរិតជីវភាពប្រជាជនក្នុងតំបន់
- ធ្វើអោយប្រសើឡើងវិញនូវធនធានជលផលនៅក្នុង និងជុំវិញតំបន់សហគមន៍

| ឈ្មោះដែនសហគមន៍ | ទំហំ | ទំហំដែលត្រូវកែលម្អ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| កបឹងរំពេរមាត់ស្ទឹងតាំងក្រសាំង | (៥០មx៥មx១ម) | (៥០មx៥មx១ម) | -ធ្វើទំនប់បង្ហៀរទឹក<br>-ធ្វើដោយគ្រឿងចក្រ | ១-៣-២០១៨ | ១-៥-២០១៨ | - ប្រភពថវិកាពី រដ្ឋាភិបាល (មូលនិធិឃុំ<br>- អង្គកានានា |

**គ.៣ រៀបចំកន្លែងអភិរក្ស**

**គោលបំណង**

- បង្កើនពូជត្រី និងសត្វគ្រប់ប្រភេទ
- ថែរក្សា ការពារព្រៃលិចទឹក ដែលជាជំរក និងប្រភពចំណីរបស់ត្រី និងសត្វ
- ផ្តល់ចំណេះដឹងដល់ប្រជាពលរដ្ឋអោយចេះស្រឡាញ់ ថែរក្សា ការពារធនធានធម្មជាតិ បរិស្ថាន និងចូលរួមលុបបំបាត់ការនេសាទខុសច្បាប់។

| ឈ្មោះទីតាំង | ទំហំ(ហិតា) | ប្រភេទនៃការអភិរក្ស | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|

| | | | | | | |
|---|---|---|---|---|---|---|
| អន្លង់កោះទង់ | ៣ហិចតា | - ពូជត្រី<br>-សត្វទឹកគ្រប់ប្រភេទ | - កំណត់ព្រំប្រទល់កន្លែងអភិរក្ស បោះបង្គោល ២០០, ដាក់ស្លាកសញ្ញាហាមឃាត់ ១២ ស្លាក<br>- ដាក់លូជំរកត្រីសិប្បនិមិត្ត ២៥<br>- លែងកូនត្រី ៣០០០០ក្បាល<br>- ផ្សព្វផ្សាយសារៈប្រយោជន៍កន្លែងអភិរក្ស និងព្រៃលិចទឹកជុំវិញបឹងរំពេរ។<br>- រៀបចំក្រុមល្បាតអនុវត្តសកម្មភាពជាប្រចាំ។ | ២០១៧ | ២០១៩ | -សុំជំនួយពីរដ្ឋាភិបាល<br>-អង្គការនានា |

### គ.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក

គោលបំណងដូចខាងក្រោម៖

- គ្រប់គ្រងព្រៃលិចទឹកអោយមាននិរន្តរភាពដើម្បីជាជម្រកត្រីពងកូន និងសត្វគ្រប់ប្រភេទ
- ផ្តល់ឱកាស និងផ្សព្វផ្សាយដល់ប្រជាពលរដ្ឋចូលរួមក្នុងការគ្រប់គ្រងធនធានធម្មជាតិ កាត់បន្ថយការបំផ្លាញ និងប្រើប្រាស់ព្រៃលិចទឹកក្នុងតំបន់ដែលគ្រប់គ្រងដោយសហគមន៍។

#### គ.៤.១ ផែនការដាំកូនឈើព្រៃលិចទឹក

| ឈ្មោះ/ទីតាំង | ទំហំ(ហ.ត) | ប្រភេទកូនឈើដែលត្រូវដាំ និងការពារ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ជុំវិញបឹងរំពេរ | ១៥ហិចតា | តាសែង ក្ទំភ្លែង អញ្ចាញ សណ្តាន់ ចំនួន១៨០០០ដើម។ | - ផ្សព្វផ្សាយពីសារៈប្រយោជន៍ព្រៃលិចទឹក។<br>- ដាំព្រៃលិចទឹកចំនួន ១៨០០០ដើម។<br>- ថែទាំ និងតាមដានជាប្រចាំនូវព្រៃលិចទឹកដែលបានដាំរួច។ | ២០១៧ | ២០១៩ | |

### គ.៥.២ ផែនការបែងចែកតំបន់គ្រប់គ្រងព្រៃលិចទឹកតាមភូមិនីមួយៗ

| ឈ្មោះ/ទីតាំង | ទំហំ (ហិតា) | ប្រភេទព្រៃលិចទឹក | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|---|---|
| ចំណុចកៀនទៀកដល់ខ្នាតកែវ | ១០ | ព្រៃលិចទឹកគ្រប់ប្រភេទក្នុងតំបន់ត្រូវការពារ | - ឃ្លាំមើល<br>- ថែទាំ | ២០១៧ | ២០១៩ | សមាជិកមកពីភូមិចំបក់ |
| ចំណុចខ្នាតកែវដល់ត្រពាំងត្រស់ | ១០ | ព្រៃលិចទឹកគ្រប់ប្រភេទក្នុងតំបន់ត្រូវការពារ | - ឃ្លាំមើល<br>- ថែទាំ | ២០១៧ | ២០១៩ | សមាជិកមកពីភូមិសង់ឃ្លាំង |
| ចំណុចកៀនទៀកដល់ត្រពាំងត្រស់ | ១០ | ព្រៃលិចទឹកគ្រប់ប្រភេទក្នុងតំបន់ត្រូវការពារ | - ឃ្លាំមើល<br>- ថែទាំ | ២០១៧ | ២០១៩ | សមាជិកមកពីភូមិទួលវិហារ |

### គ. ៥ ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

**គោលបំណង**

- បង្កើនប្រាក់ចំណូល
- កាត់បន្ថយការចាប់ត្រីក្នុងដែននេសាទ
- អភិវឌ្ឍន៍ចំណេះដឹងផ្នែកវារីវប្បកម្មដល់សមាជិកសហគមន៍

| ប្រភេទវារីវប្បកម្ម | ចំនួន | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រីពូជ | ខែ/ឆ្នាំ | | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | ប្រមូលផល | |
| ចិញ្ចឹមត្រីក្នុងស្រះ | ២០គ្រួសារ<br>ទំហំ ១០មx១៥ម | ត្រីអណ្តែង<br>ត្រីក្រាញ់<br>ត្រីទីឡាព្យា | ៤០០០០ក្បាល | ០១/២០១៨ | ០៦/២០១៨ | ស្នើសុំអង្គការ |

### គ. ៥ ផែនការអភិវឌ្ឍន៍មុខរបរទ្រទ្រង់ជីវភាព

**គោលបំណង**

- ដើម្បីអោយប្រជាពលរដ្ឋមានមុខរបរ បង្កើនប្រាក់ចំណូល
- ជួយកាត់បន្ថយអត្រាចំណាកស្រុក
- ផ្តល់ចំណេះដឹង ជំនាញ និងបច្ចេកទេស
- បង្កើនការចូលរួមសហគមន៍នេសាទ

| ប្រភេទមុខរបរ | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|
| ដាំបន្លែ ១៧គ្រួសារ | - ជ្រើសរើសកសិករគម្រូ<br>- បណ្តុះបណ្តាលបច្ចេកទេស<br>- ដាំបន្លែតាមប្រព័ន្ធកសិកម្មសមស្របជាក់ស្តែងជាមួយកសិករ | ១/២០១៨ | ១២/២០១៨ | ស្នើសុំ (ថវិកា និងបច្ចេកទេស) |
| កែច្នៃផលនេសាទ ៥ គ្រួសារ | - ជ្រើសរើសកសិករគំរូ។<br>- បណ្តុះបណ្តាលបច្ចេកទេស។<br>- រៀបចំសម្ភារៈដំណើរការកែច្នៃ និងទុកដាក់ វេចខ្ចប់។ | ៨/២០១៨ | ១២/២០១៩ | ស្នើសុំ (ថវិកា និងបច្ចេកទេស) |

### គ.៦ ផែនការអភិវឌ្ឍន៍កម្មវិធីចំរុះ

**គោលបំណង**

- បង្កើនប្រាក់ចំណូល និងកែលម្អជីវភាពសមាជិកសហគមន៍
- សមាជិកសហគមន៍បានយល់ដឹងពីបញ្ហាសុខភាព អនាម័យ និងការអប់រំបរិស្ថាន
- ពង្រឹងសហគមន៍ និងបង្កើនការយល់ដឹងនៅក្នុងសហគមន៍

| ប្រភេទមុខរបរ | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|
| រៀបចំក្រុមសន្សំប្រាក់ឡើងវិញ ៦ក្រុម និងបន្ថែមក្រុមសន្សំថ្មីចំនួន ៣ក្រុម។ | - ផ្សព្វផ្សាយគោលការណ៍ក្រុមសន្សំ<br>- បណ្តុះបណ្តាលការចុះបញ្ជីស្នាមក្រុម<br>- ការសន្សំប្រាក់ ការធ្វើឥណទាន<br>- ការតាមដាន និងត្រួតពិនិត្យ | ២០១៧ | ២០១៩ | ស្នើសុំអង្គការដៃគូរនានា |
| កម្មវិធីទឹកស្អាត សុខភាព អនាម័យ និងបរិស្ថាននៅមូលដ្ឋានបឋម។ | - ផ្សព្វផ្សាយ បរិស្ថាន សុខភាព អនាម័យ<br>- ធ្វើផែនការសំអាតបរិស្ថាន និងអនាម័យភូមិ។<br>- ផ្សព្វផ្សាយអោយប្រជាពលរដ្ឋប្រើប្រាស់ទឹកស្អាត។ | ២០១៧ | ២០១៩ | ស្នើសុំអង្គការដៃគូរនានា |

### គ. ៧ ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ

**គោលបំណង**

- បង្កើនសមត្ថភាពគណៈកម្មការសហគមន៍នេសាទ
- ពង្រឹងសហគមន៍នេសាទ
- មានសាមគ្គីភាព និងទំនាក់ទំនងល្អ

| ប្រភេទវគ្គបណ្តុះបណ្តាល | គ្រូបង្គោល | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|
| -វិធីសាស្ត្រ និងអត្ថប្រយោជន៍ស្តីពីការគ្រប់គ្រងធនធានជលផល<br>-ភាពជាអ្នកដឹកនាំ | រដ្ឋបាលជលផល | កក្កដា ២០១៧ | មិនា ២០១៩ | ៤ថ្ងៃ |
| វិធីសាស្ត្រស្វែងរកថវិកា និងការសរសេរគម្រោងសំណើសុំថវិកា | រដ្ឋបាលជលផល | តុលា ២០១៧ | តុលា ២០១៧ | |
| បង្កើនការយល់ដឹងពីច្បាប់ជលផល | រដ្ឋបាលជលផល | វិច្ឆិកា ២០១៧ | វិច្ឆិកា ២០១៧ | ៣ថ្ងៃ |
| វិធីសាស្ត្រដោះស្រាយទំនាស់ | រដ្ឋបាលជលផល | ធ្នូ ២០១៧ | ធ្នូ ២០១៧ | ៣ថ្ងៃ |
| រៀបចំទស្សនៈកិច្ចសិក្សា | អង្គការហ្វេក | មិថុនា ២០១៧ | ២០១៩ | |

### គ.៨ ផែនការផ្សព្វផ្សាយបណ្តុះបណ្តាលបង្កើនការយល់ដឹង

**គោលបំណង**

- ពង្រឹងសហគមន៍នេសាទ
- បង្កើនសមត្ថភាពគណៈកម្មការ សមាជិកសហគមន៍ និងអ្នកពាក់ព័ន្ធទាំងអស់
- កាត់បន្ថយសកម្មភាពបទល្មើសនេសាទនៅក្នុងមូលដ្ឋាន

- សមាជិកសហគមន៍នេសាទទទួលបានចំណេះដឹង និងបច្ចេកទេសថ្មីៗដើម្បីបង្កើនមុខរបរ និងប្រាក់ចំណូល

| ផែនការ | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ | ក្រុមគោលដៅ | ផ្សេងៗ |
|---|---|---|---|---|---|
| ប្រជុំផ្សព្វផ្សាយ | លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ | ២០១៧ | ២០១៩ | គណៈកម្មការស.ន សមាជិក អ្នកពាក់ព័ន្ធ | ស្នើសុំជលផល និងអង្គការនានា |
| | ច្បាប់ជលផល | ២០១៧ | ២០១៩ | គណៈកម្មការស.ន សមាជិក អ្នកពាក់ព័ន្ធ | ស្នើសុំជលផល និងអង្គការនានា |
| | ផលប៉ះពាល់ការប្រើប្រាស់ថ្នាំពុល | ២០១៧ | ២០១៨ | គណៈកម្មការស.ន សមាជិក អ្នកពាក់ព័ន្ធ | ស្នើសុំជលផល និងអង្គការនានា |
| | សារៈប្រយោជន៍តំបន់អភិរក្ស និងព្រៃលិចទឹក | ២០១៧ | ២០១៨ | គណៈកម្មការស.ន សមាជិក អ្នកពាក់ព័ន្ធ | ស្នើសុំជលផល និងអង្គការនានា |

**គ. ៩ ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍**

**គោលបំណង**

- ដើម្បីអោយគណៈកម្មការ និងសមាជិកសហគមន៍នេសាទអនុវត្តន៍ផែនការបានជោគជ័យ
- មានថវិកាគ្រប់គ្រាន់ដើម្បីអភិវឌ្ឍន៍សហគមន៍នេសាទ

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ | ចំណូលសរុប | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានប្រចាំឆ្នាំ | គណៈកម្មការចុះប្រមូលប្រាក់ភាគទានប្រចាំឆ្នាំ។ | ២០១៧ | ២០១៩ | ៣០០០០០៛ | សហគមន៍ |
| ជំនួយសប្បុរសជន និងអង្គការនានា។ | -សរសេរគម្រោង<br>-ផ្សព្វផ្សាយដល់សប្បុរសជន។ | ២០១៧ | ២០១៩ | ២៤,០០០,០០០៛ | សុំជំនួយ |

## ឃ. យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ ត្រូវមានយុទ្ធសាស្ត្រមួយចំនួន ដូចខាងក្រោមៈ

- បង្កើតគណៈកម្មការសម្រាប់អនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តន៍ផែនការ រួមមានៈ សមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ និងសមាជិកសហគមន៍នេសាទដែល មានបទពិសោធន៍ និងចណេះដឹងល្អៗ ។
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែលទាក់ទងនឹងបច្ចេកទេសជលផលដូចជាៈ ធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រៃក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកថវិកាទ្រទ្រង់ និងដៃគូរគាំទ្រ ជាដើម។
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗដោយជាក់លាក់។
- ទាក់ទងជាមួយរដ្ឋបាលជលផលដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសំរាប់ទ្រទ្រង់ផែនការគ្រប់គ្រង សហគមន៍នេសាទ។

- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធ សំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ។
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ។
- រៀបចំវិធានការទប់ស្កាត់ការហូរចូលចំពោះអ្នកនេសាទមកពីក្រៅសហគមន៍។
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងដល់គណៈកម្មការសហគមន៍នេសាទ។
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ។
- បញ្ចូលផែនការការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការនៃកម្មវិធីវិនិយោគឃុំ/សង្កាត់។

**តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍នេសាទបឹងរំពេររយៈពេល ៣ ឆ្នាំ (២០១៧ ដល់ ២០២០)**

| ផែនការគ្រប់គ្រងកន្លែងអភិរក្ស | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ | ប្រភពជំនួយ | ពេលចាប់ផ្ដើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| **១. ការប្រើប្រាស់ឧបករណ៍នេសាទ** | - កំណត់កន្លែងនេសាទ<br>- កំណត់ប្រភេទ និងទំហំឧបករណ៍នេសាទ និងចំនួនមនុស្សដែលអាចអនុញ្ញាតអោយចូលនេសាទបានក្នុង ១ថ្ងៃ<br>- ផ្សព្វផ្សាយពីការកំណត់ទំហំឧបករណ៍នេសាទក្នុងកន្លែងនេសាទដល់សមាជិក និងអ្នកក្រៅសមាជិក។<br>- ចុះត្រួតពិនិត្យ និងតាមដានជាប្រចាំ។ | - ផលត្រីអាចកើនឡើង និងអាចកាត់បន្ថយបាននូវការប្រើប្រាស់ឧបករណ៍ល្មើសច្បាប់ក្នុងដែនសហគមន៍<br>- អ្នកនេសាទនៅក្នុងកន្លែងសហគមន៍គ្រប់គ្រង នឹងអាចយល់ដឹងពីការគ្រប់គ្រងរបស់សហគមន៍ | - ចំណាយលើការត្រួតពិនិត្យ និងតាមដាន ៤០០០ ០០០៛ ក្នុង ១ឆ្នាំ<br>- ចំណាយលើការផ្សព្វផ្សាយ ២ ០០០ ០០០៛ | - វិភាគទានសហគមន៍ និងសប្បុរសជន<br>- អង្គការនានា<br>- ខណ្ឌជលផល | ២០១៧ | ២០១៩ | រាល់ឆ្នាំ |
| **២. កែលម្អដែននេសាទ** | លើកទំនប់បង្ហៀរនៅត្រង់ចន្លោះកបឹងរំពេរ និងមាត់ស្ទឹងតាំងក្រសាំងប្រវែង ៥០ម ទទឹង ៥ម និងកំពស់ ១ម ដើម្បីទប់ទឹកបឹងអោយបានច្រើនគ្រប់គ្រាន់<br>- អនុវត្តន៍លើកទំនប់ដោយគ្រឿងចក្រ<br>- រៀបចំក្រុមការងារទទួលខុសត្រូវតាមដានការអនុវត្ត ត្រួតពិនិត្យ និងជួសជុលជាប្រចាំ | - អាចរក្សាទឹកបានច្រើន<br>- បទល្មើសថយចុះ<br>- ប្រើប្រាស់ទឹកបានគ្រប់គ្រាន់<br>- ព្រៃលិចទឹកកើនឡើងច្រើន<br>- ធនធានជលផលកើនឡើង | ៥០០០០ ០០០៛ | - សប្បុរសជន<br>- រាជរដ្ឋាភិបាល<br>- អង្គការនានា | ខែ ៣ ឆ្នាំ ២០១៨ | ខែ ៥ ឆ្នាំ ២០១៨ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| **៣.កំណត់ និងរៀបចំកន្លែងអភិរក្ស** | -កំណត់កន្លែងអភិរក្ស និងបោះបង្គោលកំណត់ព្រំប្រទល់<br>-បោះស្លាកសញ្ញាកន្លែងអភិរក្ស និងការហាមឃាត់<br>- ផ្សព្វផ្សាយកន្លែងអភិរក្ស<br>- ដាក់ជំរកសិប្បនិម្មិត<br>- លែងកូនត្រី និងត្រីមេពូជ<br>- រៀបចំក្រុមល្បាត | - អន្លង់អភិរក្សត្រីមេពូជ ១ទំហំ ៣ហិតាបានបង្កើត និងបោះបង្គោល ១២ ស្លាកសញ្ញាហាមឃាត់ ៤<br>- ត្រី និងសត្វគ្រប់ប្រភេទសម្បូរឡើងវិញ<br>កូនត្រីចំនួន ៦០០០០ក្បាលនឹងត្រូវបានលែង | ១០០០០ ០០០៛ ក្នុង ១ឆ្នាំ ដើម្បីការថែទាំ យាមល្បាត និងផ្សព្វផ្សាយ<br>-សម្ភារៈ និងថវិកាសម្រាប់រៀបចំអភិរក្សអន្លង់កោះទុងអនុវត្តតាមការជាក់ស្តែង។ | - សប្បុរសជន<br>- រាជរដ្ឋាភិបាល<br>- អង្គការនានា | ២០១៧ | ២០១៩ | |
| **៤. ការគ្រប់គ្រងព្រៃលិចទឹក** | - រៀបចំបែងចែកតាមភូមិដើម្បីទទួលខុសត្រូវគ្រប់គ្រង និងការងារព្រៃលិចទឹកចំនួន ៣កន្លែងមានទំហំសរុបប្រមាណ ៣០ហិតា ។<br>- មានភូមិចំបក់ជើង(ចំណុចកៀនទៀកដល់ខ្នាតកែវ), សង់ឃ្លាំងពីចំណុចខ្នាតកែវដល់ត្រពាំងត្រស់ និងភូមិទួលវិហារចំណុចកៀនទៀកដល់ត្រពាំងត្រស់។<br>- ភូមិនីមួយៗត្រួតពិនិត្យតាមដាន និងទប់ស្កាត់ការកាប់បំផ្លាញព្រៃលិចទឹកជាប្រចាំ។ | -ព្រៃលិចទឹកត្រូវបានការការពារត្រឹមត្រូវ<br>-ត្រី និងវារីសត្វគ្រប់ប្រភេទសម្បូរឡើងវិញ<br>-មានការចូលរួមពីសហគមន៍ច្រើន | ៥ ០០០ ០០៛ ក្នុង១ឆ្នាំ | - សប្បុរសជន<br>- រាជរដ្ឋាភិបាល<br>- អង្គការនានា | ២០១៧ | ២០១៩ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៥. អភិវឌ្ឍន៍ វារីវប្បកម្ម | - បណ្តុះបណ្តាលបច្ចេកទេសពីការចិញ្ចឹមត្រីក្នុងស្រះ ។<br>- ចងក្រងក្រុមចិញ្ចឹមត្រី<br>- ត្រួតពិនិត្យ និងតាមដាន | - សមាជិកសហគមន៍ចំនួន ២០គ្រួសារមានជំនាញក្នុងការចិញ្ចឹមត្រី ។<br>- សមាជិកចំនួន២០គ្រួសារត្រូវបានចងក្រងជាក្រុមចិញ្ចឹមត្រី។<br>- បានធ្វើការត្រួតពិនិត្យ និងតាមដានពីសកម្មភាពចិញ្ចឹងត្រី។ | ចំណាយលើការផ្សព្វផ្សាយ ៣០០០០០០៛ ក្នុង១ឆ្នាំ | - បច្ចេកទេស និងថវិកា<br>- អង្គការដៃគូរនានា | ២០១៧ | ២០១៧ | |
| ៦. អភិវឌ្ឍន៍កម្មវិធីចម្រុះ | - បង្កើតក្រុមសន្សំប្រាក់បង្កើតកម្មវិធីទឹកស្អាតសុខភាព អនាម័យ និងអប់រំបរិស្ថាននៅមូលដ្ឋាន<br>- ផ្សព្វផ្សាយ និងតាមដានការអនុវត្តន៍គ្រប់សកម្មភាពខាងលើ។ | - សមាជិកប្រមាណ ១៥%អាចបង្កើនប្រាក់ចំណូល។<br>- សមាជិកសហគមន៍ ៦០%នឹងយល់ដឹងពីអនាម័យ ការប្រើប្រាស់ទឹកស្អាត សុខភាព និងថែរក្សាអនាម័យភូមិ។ | ២២០០០០០ រៀល | - សប្បុរសជន<br>- រាជរដ្ឋាភិបាល<br>- អង្គការដៃគូរនានា | ២០១៧ | ២០១៩ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| **៧. ពង្រឹងគណៈកម្មការសហគមន៍នេសាទ** | - បណ្តុះបណ្តាលផ្នែករដ្ឋបាល<br>- បណ្តុះបណ្តាលចំណេះដឹងផ្នែកគ្រប់គ្រង<br>- រៀបចំក្រុមល្បាត និងឃ្លាំមើលដែនសហគមន៍<br>- រៀបចំបណ្តាញសហគមន៍<br>- ទស្សនៈកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍។ | - មានចំណេះលើការរៀបទុកដាក់ឯកសារ សរសេររបាយការណ៍ កំណត់ហេតុ និងលិខិតស្នាម។<br>- ចេះដោះស្រាយទំនាស់ មានជំនាញសម្របសម្រួល។<br>- មានការយាម ល្បាត និងមានផែនការល្បាតត្រឹមត្រូវក្នុងកន្លែងនេសាទ បទល្មើសនឹងថយចុះ។<br>- ការប្រមូលពត៌មានក្នុងសហគមន៍ និងទទួលពត៌មានពីខាងក្រៅទាន់ពេលវេលា និងសហគមន៍ចេះធ្វើការងារជាបណ្តាញ។<br>- សហគមន៍មានការផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមក។ | - ចំណាយលើសម្ភារៈ និងមធ្យោបាយក្នុងការល្បាត ៦០០០០០០៛<br>- ការបណ្តុះបណ្តាលផ្សព្វផ្សាយ និងត្រួតពិនិត្យ ១៥០០០០០៛<br>- ទស្សនៈកិច្ចសិក្សា ៨០០០០០៛ | - សប្បុរសជន<br>- រាជរដ្ឋាភិបាល<br>- អង្គការនានា | ២០១៧ | ២០២០ | |
| **៨. ផ្សព្វផ្សាយបណ្តុះបណ្តាលបង្កើនការយល់ដឹង** | - ផ្សព្វផ្សាយការគ្រប់គ្រងសហគមន៍(លក្ខខន្តិកៈ បទបញ្ជាផ្ទៃក្នុង ផែនទីកន្លែងនេសាទ ផែនការគ្រប់គ្រងសហគមន៍ ច្បាប់ជលផល...)<br>ការកែច្នៃជលផល។ | -សមាជិកសហគមន៍ប្រមាណ ៧០-៨០% យល់ដឹងពីការគ្រប់គ្រងសហគមន៍ បទបញ្ជាផ្ទៃក្នុង ផែនទីកន្លែងនេសាទ ផែនការគ្រប់គ្រងសហគមន៍ ច្បាប់ជលផល...)។ | ចំណាយ ១ ០០០ ០០០ រៀលក្នុង ១ឆ្នាំ | - សប្បុរសជន<br>- រាជរដ្ឋាភិបាល<br>- អង្គការនានា | ២០១៧ | ២០១៩ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៩. ថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ | -ប្រមូលវិភាគទានប្រចាំឆ្នាំ<br>-ស្វែងរកថវិកាពីរដ្ឋាភិបាល សប្បុរសជន និងអង្គការនានា<br>-ផ្សព្វផ្សាយដើម្បីស្វែងរកថវិកា និងជំនួយ | -ត្រូវបានប្រមូលប្រាក់វិភាគទានប្រចាំឆ្នាំ<br>-ថវិកាមួយចំនួននឹងត្រូវបានផ្តល់សម្រាប់ទ្រទ្រង់សហគមន៍ដោយអង្គការនានារដ្ឋាភិបាល និងសប្បុរសជន<br>-ទឹកប្រាក់ចំនួន៥០០០០០៛ នឹងបានប្រមូលប្រាក់វិភាគទានពីសមាជិក<br>-ការប្រាក់ចំនួន២ភាគរយ ទទួលបានពីក្រុមសន្សំនៃសហគមន៍។ | ៧០០០០០៛ | - សប្បុរសជន<br>- រាជរដ្ឋាភិបាល<br>- អង្គការនានា<br>- សមាជិកសហគមន៍ និងអ្នកពាក់ព័ន្ធ | ២០១៧ | ២០១៩ | |

## តារាងកម្មវិធីការងារ

| សកម្មភាព | កាលបរិច្ឆេទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ឆ្នាំ២០១៧ | | | | | | | | ឆ្នាំ២០១៨ | | | | | | | | | | | | ឆ្នាំ២០១៩ | | | | | | | | | | | |
| | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| ១. ការប្រើប្រាស់ ឧបករណ៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ១.១ កំណត់កន្លែងនេសាទ កំណត់ប្រភេទ និងទំហំឧបករណ៍នេសាទ | | | | | | | | | | | | | — | → | | | | | | | | | | — | — | → | | | | | | |
| ១.២ ផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ | — | — | — | → | | | | | | | | | — | — | — | → | | | | | | | | | — | — | → | | | | | |
| ១.៣ ចុះត្រួតពិនិត្យ តាមដានជា ប្រចាំ | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | → |
| ២. កែលម្អដែននេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ២.១ លើកទំនប់បង្ខៀរនៅត្រង់ចន្លោះកបឹងរំពេរ និងមាត់ស្ទឹងកាំងក្រសាំង | | | | | | | | | | | — | — | → | | | | | | | | | | | | | | | | | | | |
| **៣.កំណត់ និងរៀបចំកន្លែងអភិរក្ស** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៣.១ បោះបង្គោលកំណត់ព្រំប្រទល់កន្លែងអភិរក្ស | | | | | | | | | | | | — | — | → | | | | | | | | | | | | | | | | | | |
| ៣.២ បោះស្លាកសញ្ញាការហាមឃាត់ | | | | | | | | | | | | | — | — | → | | | | | | | | | | | | | | | | | |
| ៣.៣ ផ្សព្វផ្សាយកន្លែងអភិរក្ស | | | | | | | | | | | | | — | → | | | | | | | | | | | | | | | | | | |
| ៣.៤ ដាក់ជំរកសិប្បនិម្មិត | | | | | — | → | | | | | | | | | | | | | | | | | | | | | | | | | | |
| ៣.៥ រៀបចំក្រុមល្បាត | | | | — | → | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៤. ការគ្រប់គ្រងព្រៃលិចទឹក | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៤.១ រៀបចំបែងចែកតាមភូមិ | | | | | | | | | | | — | — | → | | | | | | | | | | | | | | | | | | | |
| ៤.២ បោះស្លាកសញ្ញាហាមឃាត់ | | | | | | | | — | — | — | | | | | | | | | | | | | | | | | | | | | | |
| ៤.៣ ផ្សព្វផ្សាយ | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | — | → |

| |
|---|
| ៨.៤ ត្រួតពិនិត្យ ថែរក្សា តាមដាន និងឃ្លាំមើលជាប្រចាំ |
| **៥. អភិវឌ្ឍន៍វារីវប្បកម្ម** |
| ៥.១ ផ្សព្វផ្សាយបច្ចេកទេសពីការចិញ្ចឹមត្រីក្នុងស្រះ |
| ៥.២ ជ្រើសរើសសមាជិកចិញ្ចឹមត្រី ២០គ្រួសារ |
| ៥.៣ បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រី |
| **៦. អភិវឌ្ឍន៍កម្មវិធីចម្រុះ** |
| ៦.១ រៀបចំក្រុមសន្សំប្រាក់ចាស់ឡើងវិញ |
| ៦.២ រៀបចំក្រុមសន្សំប្រាក់ថ្មីចំនួន ៣ក្រុម |
| ៦.៣ កម្មវិធីទឹកស្អាត សុខភាព អនាម័យ |
| ៦.៤ ពង្រឹងក្រុមកែច្នៃផលនេសាទ បង្កើតក្រុមកែច្នៃថ្មី ១ទៀត |
| ៦.៥ រៀបចំក្រុមដាំបន្លែ |
| **៧. ពង្រឹងគណៈកម្មការសហគមន៍នេសាទ** |
| ៧.១ បណ្តុះបណ្តាលផ្នែករដ្ឋបាល |
| ៧.២ ការគ្រប់គ្រង ហិរញ្ញវត្ថុ |
| ៧.៣ បណ្តុះបណ្តាលចំណេះដឹងផ្នែកគ្រប់គ្រង |
| ៧.៤ ទស្សនៈកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ |
| **៨. ពង្រឹងការល្បាត និងឃ្លាំមើលបទល្មើសនេសាទ** |
| ៨.១ រៀបចំក្រុមល្បាត និងចុះល្បាត |
| ៨.២ រៀបចំសម្ភារៈល្បាត និងចុះល្បាត |

| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **៩. ផ្សព្វផ្សាយ និងបង្កើតការយល់ដឹង** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៩.១ ផ្សព្វផ្សាយការគ្រប់គ្រងសហគមន៍(លក្ខខន្តិកៈ បទបញ្ជាផ្ទៃក្នុង) | | → | | | | | | | | → | | | | | | | | | | | | → | | | | | | | | | | |
| ៩.២ ផ្សព្វផ្សាយ និងបង្កើតការយល់ដឹង(សារៈប្រយោជន៍ព្រៃលិចទឹកផលប៉ះពាល់បរិស្ថាន...) | → | | | | | | | | → | | | | | | | | | | | | | → | | | | | | | | | | |
| **១០. ថវិកាទ្រទ្រង់សហគមន៍** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ១០.១ ប្រមូលវិភាគទានប្រចាំឆ្នាំ | | | | | | | | → | | | | | | | | | | | → | | | | | | | | | | | | | → |
| ១០.២ ផ្សព្វផ្សាយដើម្បីស្វែងរកថវិកា និងជំនួយ | → | | | | | | | | → | | | | | | | | | | | | → | | | | | | | | | | | |

សូមគោរពជូន

**លោកមេឃុំតាំងក្រសាំង**

" ដើម្បីជូនពិនិត្យនិងសម្រួល "

.........ថ្ងៃទី.៣០..ខែ.មករា ឆ្នាំ២០១៧

**ប្រធានគណៈកម្មការសហគមន៍នេសាទ**
**បឹងរំពេរ**

ស៊ាគាម

លេខ:...៣៧/១៧...

បានឃើញនិងគោរពជូន

លោកនាយសង្កាត់រដ្ឋបាលជលផលសន្ទុក

"ដើម្បីជូនពិនិត្យនិងសម្រួល"

តាំងក្រសាំងថ្ងៃទី.៣០...ខែមករាឆ្នាំ២០១៧

**មេឃុំ**

**នី សុខណ្ណ**

បានឃើញនិងគោរពជូន

លោកនាយផ្នែករដ្ឋបាលជលផលប្រាសាទសំបូរ

"ដើម្បីជូនពិនិត្យនិងសម្រួល"

...........ថ្ងៃទី.៣០....ខែមករាឆ្នាំ២០១៧

**នាយសង្កាត់រដ្ឋបាលជលផលសន្ទុក**

ពិន សុភា

លេខ:........................

បានឃើញនិងគោរពជូន

លោកនាយខណ្ឌរដ្ឋបាលជលផលកំពង់ធំ

"ដើម្បីជូនពិនិត្យនិងសម្រួល"

...........ថ្ងៃទី.៣០....ខែមករាឆ្នាំ២០១៧

**នាយផ្នែករដ្ឋបាលជលផលប្រាសាទសំបូរ**

គួ ប៊ុនធឿន

លេខ :..២១៤...រដ្ឋ.កធ

បានឃើញនិងគោរពជូន

លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-ខេត្តកំពង់ធំ-

" ដើម្បីជូនពិនិត្យនិងសម្រួល "

កំពង់ធំ ថ្ងៃទី.៣០.ខែមករា ឆ្នាំ២០១៧

**នាយខណ្ឌរដ្ឋបាលជលផលកំពង់ធំ**

ម៉ើន_វណ្ណរិទ្ធ

លេខ ៤២៨៣ មករា.ខ

បានឃើញនិងគោរពជូន

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

" ដើម្បីជូនពិនិត្យនិងសម្រេចដោយអនុគ្រោះ "

កំពង់ធំថ្ងៃទី.៣១..ខែ.មករា.ឆ្នាំ២០១៧.

**ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**-ខេត្តកំពង់ធំ-**

**ធីវ វណ្ណធីរ**

លេខ:..៣១១៦.....ជជ

បានឃើញនិងឯកភាព

រាជធានីភ្នំពេញ ថ្ងៃទី.០៤.. ខែ..មករា.ឆ្នាំ២០១៨.

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**
**ប្រធានរដ្ឋបាលជលផល**

**អេង ជាសាន**